**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣០០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៧១ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលហៅថា អគ្គលេខាធិការដ្ឋាន **គ.យ.ប.**។

## ជំពូកទី២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.យ.ច.

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាន **គ.យ.ច.** មានតួនាទីជាសេនាធិការឱ្យ **គ.យ.ច.** និងមានភារកិច្ចដូចតទៅៈ

- ដឹកនាំនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជូន **គ.យ.ច.** ពិនិត្យនិងសម្រេច
- ចូលរួមកំណត់សមិទ្ធផល រៀបចំសូចនាករសមិទ្ធកម្មគន្លឹះ និងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលដឹកនាំសម្របសម្រួលក្នុងកម្រិតបច្ចេកទេសដោយស្ថាប័នដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ
- សហការ សម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការអន្តរក្រសួង ស្ថាប័ន និងក្រុមប្រឹក្សា ក្នុងការតម្រង់ទិសកម្រិតគោលនយោបាយតាមការចង្អុលបង្ហាញរបស់ **គ.យ.ច.** ដើម្បីពន្លឿនការអនុវត្តយុទ្ធសាស្ត្រ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព
- ពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកិច្ចការពាក់ព័ន្ធនឹងយុទ្ធសាស្ត្របញ្ចកោណរបស់ក្រសួង ស្ថាប័ន និងលើកយោបល់ជូន **គ.យ.ច.** ព្រមទាំងវាស់វែងលទ្ធផលធៀបនឹងសូចនាករសមិទ្ធកម្មគន្លឹះ និងវាយតម្លៃកម្មវិបាក តាមរយៈការចុះអង្កេត និងប្រមូលទិន្នន័យ
- កំណត់បញ្ហាប្រឈមដែលរាំងស្ទះដល់ការសម្រេចបាននូវកិច្ចការអាទិភាពដែលបានគូសរំលេចក្នុងយុទ្ធសាស្ត្របញ្ចកោណ ដើម្បីស្នើឡើងនូវវិធានការចាំបាច់បន្ថែមនានា
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងស្ថាប័នស្រាវជ្រាវពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលបន្ថែមក្នុងការគាំទ្រដល់ការតាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រឱ្យមានភាពគ្រប់ជ្រុងជ្រោយ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីវឌ្ឍនភាពនិងលទ្ធផលនៃការតាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- សម្របសម្រួលនិងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **គ.យ.ច.**
- ចាត់ចែងនិងគ្រប់គ្រងសម្ភារៈបរិក្ខាររបស់ **គ.យ.ច.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងថវិការបស់ **គ.យ.ច.**
- រៀបចំរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ប្រចាំឆមាស ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិជូន **គ.យ.ច.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.យ.ច.**។

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន **គ.យ.ច.** ដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមការបែងចែកពីអគ្គលេខាធិការ។

**មាត្រា៤ .-**

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន **គ.យ.ច.** គឺជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈនៃទីស្តីការគណៈរដ្ឋមន្ត្រី និង/ឬក្រសួង ស្ថាប័នផ្សេងតាមការចាំបាច់។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.យ.ច.** អាចស្នើសុំមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

អគ្គលេខាធិការដ្ឋាន **គ.យ.ច.** អាចជ្រើសរើសទីប្រឹក្សា និងអ្នកជំនាញការជាតិឬអន្តរជាតិ ដើម្បីជួយដល់ការងារអគ្គលេខាធិការដ្ឋាន ដោយមានការឯកភាពពីប្រធាន គ.យ.ច.។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ